ប្រការ ៣ ៖ គណៈកម្មការនេះត្រូវប្រជុំគ្នាតាមពេលកំណត់ដោយប្រធានគណៈកម្មការ ។

ប្រការ ៤ ៖ ភោជនីយដ្ឋាន ភេសជ្ជដ្ឋាន សប្បាយដ្ឋាន ឬ ទីកន្លែងលំហែ ដែលអាចចាត់ថ្នាក់ជាគ្រឹះស្ថានធំគឺត្រូវមានចរិកលក្ខណៈដូចតទៅ ៖

_ មានទីតាំងនៅក្នុងសណ្ឋាគារ ផ្ទះសំណាក់ ឬ ជាឧបសម្ព័ន្ធនៃសណ្ឋាគារ ឬ ផ្ទះសំណាក់

_ មានទីតាំងបំពាក់ដោយម៉ាស៊ីនត្រជាក់

_ មានទីតាំងនៅកណ្តាលវាល បើកលក់ម្ហូបចំណី នៅពេលរាត្រី និង មានការផ្តត់ផ្គង់សេវាជាលក្ខណៈអន្តរជាតិ ឬ លក្ខណៈជាតិកំរិតខ្ពស់

ប្រការ ៥ ៖ ប្រធាននាយកដ្ឋានពន្ធដារ នាយកដ្ឋាននានា នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដែលមានការពាក់ព័ន្ធដូច មានចែង ក្នុងប្រការ ២ ខាងលើ ត្រូវមានភារកិច្ចអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ទេសរដ្ឋមន្ត្រី
និង ជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
ហត្ថលេខា និង ត្រា
**សម រង្ស៊ី**

*រាជធានីភ្នំពេញ ,ថ្ងៃទី ២៨ ខែ កុម្ភៈឆ្នាំ ១៩៩៤*

# ប្រកាសលេខ ០២១ ប្រក.សហវ
# ស្តីពីការគ្រប់គ្រងប្រមូលពន្ធលើឈ្នួលផ្ទះ និង ដី

ទេសរដ្ឋមន្ត្រី និង ជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

_ បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

_ បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណា ព្រះបាទសម្តេចព្រះនរោត្តម សីហនុវរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា

_ បានឃើញព្រះរាជក្រឹត្យ របស់ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម សីហនុវរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរដ្ឋមន្ត្រី និង រដ្ឋលេខាធិការ និង អនុរដ្ឋលេខាធិការដ្ឋាននៅតាមក្រសួងស្ថាប័ន

_ បានឃើញច្បាប់ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីអំពីហិរញ្ញវត្ថុសំរាប់ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើដោយព្រះរាជក្រមលេខ ០២ នស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣

_ បានឃើញការចាំបាច់ នៃការងារសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បច្ចុប្បន្ន

## សំរេច

**ប្រការ ១ :** ពន្ធលើឈ្នួលផ្ទះ និង ដី ត្រូវបានកំណត់យកលើគ្រប់ករណីជួលទាំងអស់ដែលបានចែងក្នុងមាត្រា ២៦ នៃច្បាប់ស្តីអំពីហិរញ្ញវត្ថុ សំរាប់ឆ្នាំ ១៩៩៤ ។

**ប្រការ ២ :** ត្រូវបានលើកលែងមិនប្រមូលពន្ធ លើឈ្នួលផ្ទះ និង ដី ចំពោះគ្រប់ករណីជួលទាំងឡាយដែលសរុបប្រាក់ ឈ្នួលប្រចាំខែក្រោម ៥០០.០០០ រ ។

**ប្រការ ៣ :** ការអនុគ្រោះអោយពន្យាពេលបង់ពន្ធ បន្ថយពន្ធ ឬ អោយរួចពន្ធអាចធ្វើទៅបានក្នុងករណីដែល អ្នកជាប់ពន្ធត្រូវទទួលនូវគ្រោះមហន្តរាយដល់ទ្រព្យសម្បត្តិ ឬ អាយុជីវិត ។

**ប្រការ ៤ :** ប្រកាសនេះមានប្រសិទ្ធភាពការអនុវត្តចាប់ពីថ្ងៃ ចុះហត្ថលេខានេះតទៅ ។

ទេសរដ្ឋមន្ត្រី
និង ជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
ហត្ថលេខា និង ត្រា
**សម រង្ស៊ី**